ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាក្រុងភ្នំពេញ

លេខ: ៧៤ ឆក.ស

ភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ 2001

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ**

**ជំរាបជូន**

**ឯកឧត្តមអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

<u>កម្មវត្ថុ</u> : ករណីសំណើសុំពិនិត្យសំរេចលើតារាងតំលៃលក់ទឹកថ្មីរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។

<u>យោង</u> : -លិខិតលេខ 348 ល.ស ចុះថ្ងៃទី 18-10-2000 របស់ឯកឧត្តមអគ្គនាយក ។

-លិខិតលេខ 3041 លស ចុះថ្ងៃទី 30-12-2000 របស់សាលាក្រុងភ្នំពេញ ។

-លិខិតលេខ 1913 សជណឧស ចុះថ្ងៃទី 14-12-2000 របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

-ចំណារឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ចុះថ្ងៃទី 26-12-2000 ។

សេក្តីដូចមានចែងក្នុងកម្មវត្ថុនិង យោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមអគ្គនាយកជ្រាបថា : ចំពោះសំណើសុំពិនិត្យសំរេចលើតារាងតំលៃលក់ទឹកថ្មីរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនោះ រាជរដ្ឋាភិបាលបានសំរេចឯកភាពលើតារាងតំលៃលក់ទឹកថ្មី សំរាប់អនុវត្តពីពេលនេះ រហូតដល់ឆ្នាំ 2003 ដូចខាងក្រោម :

| ប្រភេទប្រើប្រាស់ទឹក | បរិមាណទឹកប្រើប្រាស់ក្នុង 1ខែ | តំលៃលក់ក្នុង 1ម³ |
|---|---|---|
| ជីវភាព | -ពី 0ម³ ដល់ 07ម³<br>-ពី 08ម³ ដល់ 15ម³<br>-ពី 16ម³ ដល់ 50ម³<br>-លើសពី 50ម³ | 550 រៀល<br>770 រៀល<br>1.010 រៀល<br>1.270 រៀល |
| អង្គភាពរដ្ឋបាលបុព្វហេតុ និងតំណាងចែកចាយបន្ត | មិនគិតអំពីបរិមាណ | 1.030 រៀល |
| អាជីវកម្ម-សេវាកម្ម ឧស្សាហកម្ម អង្គភាពស្វយ័ត និងអ្នកលក់ទឹក | -ពី 0ម³ ដល់ 100ម³<br>-ពី 101ម³ ដល់ 200ម³<br>-ពី 201ម³ ដល់ 500ម³<br>-លើសពី 500ម³ | 950 រៀល<br>1.150 រៀល<br>1.350 រៀល<br>1.450 រៀល |

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើ ចាប់ពីថ្ងៃទី 01 ខែមករា ឆ្នាំ 2001 តទៅ ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ**

**អភិបាល**

**សែម សុខ**

លេខ ០២៥ ជ.ល

**បានថតចម្លង**

**ត្រឹមត្រូវតាមច្បាប់ដើម**

ភ្នំពេញ ថ្ងៃទី ... ឆ្នាំ២០០៣

ជ.អគ្គនាយក

អគ្គនាយករង

**សែម ប៊ុនហេង**

<u>ចំលងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "<u>ដើម្បីជូនជ្រាបជាពត៌មាន</u>"
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "<u>ដើម្បីជាពត៌មាន</u>"
- កាលប្បវត្តិ-ឯកសារ